ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA (COMFREL)

ទីស្នាក់ការកណ្តាលផ្ទះលេខ១៣៨ ផ្លូវ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150 Fax: (855) 23 885 745
E-mail: comfrel@online.com.kh Website: http://www.comfrel.org

**គណៈកម្មាធិការនាយក**
BOARD OF DIRECTORS

1. **លោក ធន សារាយ**
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

2. **លោក សុក សំអឿន**
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

3. **លោក យង់ គិមអេង**
Mr. YONG Kim Eng
អគ្គហេរញ្ញិក -នាយកប្រតិបត្តិ
PDP-Center

4. **លោក យឹម ប៉ូ**
Mr. YIM Po នាយករង
CPDEW

5. **អ្នកស្រី ស៊ុន ចាន់សែន**
Mrs. SUN Chansen
ឥស្សរជន– Dignitary

6. **លោក ម៉ាក់ ចំរើន**
Mr. MAK Chamroeun
ប្រធាន KYA

7. **អ្នកស្រី ប៉ុក បញ្ញាវិចិត្រ**
Mrs. POK Panhavichetr
នាយិកាប្រតិបត្តិ CWCC

8. **លោក មុំ សារិន**
Mr. MOM Sarin
នាយក HRCDO

9. **លោកស្រី ពឹង យក់ហៀប**
Ms. PEUNG Yok Hiep
ឥស្សរជន-Dignitary

10. **លោក គីម សុវណ្ណ**
Mr. KIM Sovann
នាយក VIGILANCE

11. **លោក ស៊ីន សែត**
Mr. SEN Set
ឥស្សរជន-Dignitary

12. **លោក ជាង សុខា**
Mr. CHEAMG Sokha
នាយកប្រតិបត្តិ YRDP

*ភ្នំពេញថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១២*

# សេចក្តីអំពាវនាវ

## ធានានូវសុវត្ថិភាពសម្រាប់បេក្ខនារី សកម្មជនស្ត្រីរបស់គណបក្សនយោបាយ និងអ្នកបោះឆ្នោតជាស្ត្រីក្នុងការចូលរួមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣

គណៈកម្មាធិការខុមហ្វ្រែល ជាអង្គការឃ្លាំមើលការបោះឆ្នោត និងកំពុងធ្វើការយ៉ាងសកម្មក្នុងការលើកស្ទួយការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ សូមអំពាវនាវដល់រាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន គ.ជ.ប និងគណបក្សនយោបាយ បន្តអនុវត្តន៍ឱ្យបានតឹងរឹងនូវវិធានការពិសេស និងអន្តរាគមន៍ក្នុងការបញ្ឈប់រាល់សកម្មភាពគំរាមកំហែង បំភិតបំភ័យ ការប្រមាថមើលងាយ ការរើសអើង ការទិញសន្លឹកឆ្នោត និងអំពើហឹង្សាលើបេក្ខនារី អ្នកបោះឆ្នោតជាស្ត្រី និងសកម្មជននយោបាយជាស្ត្រីដែលបានកើតឡើងក្នុងដំណើរការការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ជាពិសេសក្នុងដំណាក់កាលយុទ្ធនាការឃោសនាបោះឆ្នោត និងអាចកើតឡើងជាបន្តបន្ទាប់នូវសកម្មភាពមិនប្រក្រតីទាំងនេះនៅថ្ងៃបោះឆ្នោតដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី០៣ ខែមិថុនា ដ៏ខ្លីខាងមុខ។

យោងតាមប្រពន្ធ័ផ្សព្វផ្សាយព័តិមាន និងរបាយការណ៏ពីអ្នកសង្កេតការណ៏របស់អង្គការខុមហ្វ្រែលបានរកឃើញថា មានកើតឡើងនូវអំពើហឹង្សា ការប្រមាថមើលងាយ ការបំភិតបំភ័យ ការរើសអើង ការទិញសន្លឹកឆ្នោត មកលើស្ត្រីជាសកម្មជនគណបក្សនយោបាយ ជាបេក្ខនារី និងអ្នកបោះឆ្នោតជាស្ត្រី ដែលមានជាក់ស្តែងដូចខាងក្រោមនេះ ÷

១- **លោកស្រី ឃី ម៉េងលីន** អាយុ៣៧ឆ្នាំ ជាសកម្មជនគណបក្ស សម រង្ស៊ី និងជាសមាជិកក្រុមប្រឹក្សាក្រុងបាត់ដំបង រស់នៅភូមិខ្សាច់ពោយ សង្កាត់វត្តគ ក្រុងបាត់ដំបង ខេត្តបាត់ដំបង បានថ្លែងថា នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ វេលាម៉ោង១០ និង៤៥នាទី មានក្មេងស្ទាវចំនួនបីនាក់ក្នុងសំលៀកបំពាក់អាវយឺត និងមួកមានស្លាកសញ្ញាគណបក្សប្រជាជនកម្ពុជា បានជិះម៉ូតូតាមឆាបរកបុករូបគាត់ និងបានវៃមួយដៃចំដើមទ្រូង និងឆ្អឹងជងកាំបិតខាងស្តាំ ខណៈដែលគាត់កំពុងដឹកនាំក្បួនសមាជិកគណបក្សសម រង្ស៊ីឃោសនានៅចំណុច វ៉ាជង្រុក ភូមិកំពង់ក្របី សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

២- គណបក្សប្រជាជនកម្ពុជា១រូប រងការចោទប្រកាន់ថា បានគំរាមសម្លុត និងបិទសិទ្ធិសេរីភាពប្រជាពលរដ្ឋមិនឱ្យយកឌីសខ្សែភាពយន្តឯកសាររបស់គណបក្សសម រង្ស៊ីទៅចាក់ឱ្យអ្នកភូមិមើលយល់ដឹងពីអត្ថន័យ និងខ្លឹមសារនៃគោលនយោបាយរបស់គណបក្ស ដើម្បីឱ្យពួកគាត់មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីធ្វើការសម្រេចចិត្តបោះឆ្នោតជ្រើសរើសមេដឹកនាំនៅថ្នាក់មូលដ្ឋាន។ លោកស្រី **អ៊ុក សាគុន** អាយុ៥៥ឆ្នាំ មានមុខរបរជាអ្នក

លក់បាយ និងកាហ្វេនៅភូមិបឹងព្រលិត ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង បានថ្លែងថា កាលពីល្ងាចថ្ងៃទី២៣ ខែឧសភា គណបក្សសម រង្ស៊ីបានដើរឃោសនានៅតាមភូមិ ដោយបានចែកខិត្តប័ណ្ណ និងឌីសខ្សែភាពយន្តឯកសារផ្សព្វផ្សាយពីគោលនយោបាយ របស់គណបក្សសម រង្ស៊ីឱ្យលោកស្រី។ លុះដល់ព្រឹកថ្ងៃទី២៤ ខែឧសភា លោកស្រីបានយកឌីសនោះចាក់ក្នុងហាងបាយឱ្យភ្ញៀវមើល ស្រាប់តែលោក **មិន គីម** ជាមន្ត្រីពន្ធដារស្រុកសំពៅលូន និងជាបេក្ខជនឈរឈ្មោះបោះឆ្នោតឃុំលេខរៀងទី៦របស់គណបក្សប្រជាជនបានស្រែកគំរាមខ្លាំងៗមិនឱ្យគាត់ចាក់ឌីសនោះទេធ្វើឱ្យគាត់មានការភ័យខ្លាច។

៣- កាលពីថ្ងៃទី១៩ ខែឧសភា នៅភូមិថ្មី ឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង អាជ្ញាធរមានការរើសអើងនិន្នាការនយោបាយសកម្មជនគណបក្សសម រង្ស៊ី។ មានករណីគ្រោះមហន្តរាយខ្យល់ព្យុះបានកើតមានឡើងដែលបង្កឱ្យមានការខូចខាតផ្ទះប្រហែល ៤ ទៅ ៥ខ្នង។ ប៉ុន្តែមានតែផ្ទះ **លោកស្រី ណុប សារ៉ែម** មួយខ្នងទេដែលរងគ្រោះខ្លាំងជាងគេ គឺខូចខាតទាំងស្រុងតែម្តង ហើយលោកស្រីបានទៅសុំឱ្យអាជ្ញាធរជួយ តែអាជ្ញាធរមិនជួយទេដោយគេបាននិយាយថា លោកស្រីគឺជាបេក្ខជនក្រុមប្រឹក្សាឃុំពីគណបក្សសម រង្ស៊ី ហេតុដូចម្តេចមិនឱ្យគណបក្សសម រង្ស៊ីជួយទៅ តែបើចង់ឱ្យអាជ្ញាធរជួយទាល់តែលោកស្រីហ៊ានសន្យាថា "បោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា"។

៤- សកម្មជនគណបក្សប្រជាជនកម្ពុជាប្រើប្រាស់ថវិកា ដើម្បីទិញទឹកចិត្តកុំឱ្យអ្នកគាំទ្រគណបក្សប្រឆាំងចូលរួមការបោះឆ្នោត។ លោក លឹម ម៉ាត ជាអនុប្រធានគណបក្សសិទ្ធិមនុស្សប្រចាំឃុំគោខ្ចកបាននិយាយថា សកម្មជនគណបក្សប្រជាជនកម្ពុជា២ ទៅ ៣នាក់បានដើរចូលផ្ទះប្រជាពលរដ្ឋប្រមាណ៣០គ្រួសារ ស្ថិតនៅ ភូមិព្រៃធំ ឃុំគោខ្ចក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ដោយឱ្យថវិកាដល់គាត់ក្នុង១នាក់ ចំនួន ២០០០រៀល ដើម្បីជាថ្នូរកុំឱ្យពួកគាត់ចូលរួមការបោះឆ្នោត ថែមទាំងប្រើពាក្យសំដីគំរាមកំហែងទៀតផង។ អ្នកសង្កេតការណ៍ខុមហ្វ្រែល បានចុះទៅកាន់ភូមិព្រៃធំផ្ទាល់ ហើយបានជួបប្រជាពលរដ្ឋម្នាក់ ឈ្មោះ **សៀង ខាត ភេទស្រី** បាននិយាយថា កាលពីថ្ងៃទី១៩ ខែឧសភា ពិតជាមានករណីនេះមែន គឺមានអនុប្រធានភូមិព្រៃធំ ឈ្មោះ **ហែម ហឿន** បានយកលុយទៅអោយគាត់ ហើយបាននិយាយប្រាប់គាត់ថា "កុំទៅបោះឆ្នោត បើសិនជា មិនឃើញម្រាមដៃប្រឡាក់ទឹកថ្នាំ គេនឹងយកអំណោយមកឱ្យថែមទៀត។

សកម្មភាពមិនប្រក្រតីទាំងនេះ ជាហេតុធ្វើឱ្យស្ត្រីមានការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន ប៉ះពាល់ដល់សិទ្ធិនយោបាយរបស់ស្ត្រី និងជាកត្តារាំងស្ទះដល់ការចូលរួមរបស់ស្ត្រីក្នុងកិច្ចការនយោបាយ។ យោងតាមច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មាត្រា១៧៨ថ្មី (មាត្រា២៣១ ចាស់កែប្រែ) បានចែងថា *អំពើគំរាមកំហែង អំពើហិង្សា ការគាបសង្កត់ ទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយ ដើម្បីរារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនអោយទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន ទិញសន្លឹកឆ្នោតដោយសម្ភារៈ ឬដោយប្រាក់កាស... ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត លុបបេក្ខភាពរបស់សាមីខ្លួន ឬលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ/និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ប្រាំលានរៀល ទៅម្ភៃប្រាំលានរៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌ*។ ជាងនេះទៅទៀត កម្ពុជាជាប្រទេសហត្ថលេខីលើអនុសញ្ញាស្តីពី

“ការលុបបំបាត់រាល់ ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ”និងបានប្តេជ្ញាខិតខំពន្លឿននូវសមភាពយេនឌ័រតាមរយៈការលើកស្ទួយការ ចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងកិច្ចការសាធារណៈ ផងដែរ ។

អាស្រ័យដោយបានពិនិត្យពិចារណាអំពីគុណសម្បត្តិ និងតំរូវការចាំបាច់ឱ្យមានតុល្យភាពយេនឌ័រក្នុងការទ្រទ្រង់នូវដំណើរការប្រជាធិបតេយ្យ គណៈកម្មាធិការខុមហ្វ្រែលសូមអំពាវនាវដល់រាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន គ.ជ.ប និងគណបក្សនយោបាយ រួមគ្នាបញ្ឈប់ និងទប់ស្កាត់សកម្មភាពទាំងឡាយណាដែលធ្វើឱ្យមានការភ័យខ្លាចដល់អ្នកបោះឆ្នោតជាស្ត្រី បេក្ខនារីឈរឈ្មោះ សកម្មជនរបស់គណបក្សនយោបាយជាស្ត្រី ប្រយោជន៍ដើម្បីឱ្យស្ត្រីចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៣នេះឱ្យបានច្រើនជាអតិបរមា ដែលមានដូចតទៅ:

១- ដើម្បី**បង្កើតបរិយាកាសល្អប្រសើរ**សំរាប់ស្ត្រី និង**ធានានូវសុវត្ថិភាព**សម្រាប់បេក្ខនារី អ្នកបោះឆ្នោតជាស្ត្រី សកម្មជនរបស់គណបក្សនយោបាយជាស្ត្រី សូមរាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន គ.ជ.ប និងគណបក្សនយោបាយ បន្តអនុវត្តន៍ឱ្យបានតឹងរឹងនូវច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងបទបញ្ជា និងនីតិវិធីរបស់គ.ជ.ប និងអន្តរាគមន៍ក្នុងការបញ្ឈប់រាល់សកម្មភាពគំរាមកំហែង បំភិតបំភ័យ ការរើសអើង ការប្រមាថមើលងាយ ការទិញសន្លឹកឆ្នោត និងអំពើហិង្សាលើអ្នកបោះឆ្នោតស្ត្រី និងសកម្មជននយោបាយជាស្ត្រី ។

២- គ.ជ.ប ត្រូវចាត់វិធានការតឹងរឹងក្នុងការអនុវត្តការដាក់ទោសទណ្ឌចំពោះជនណា គណបក្សនយោបាយណាដែលបានប្រព្រឹត្តអំពើណាមួយដែលផ្ទុយនឹងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងបទបញ្ជា និងនីតិវិធីរបស់គ.ជ.ប ។

៣- គណបក្សនយោបាយទាំងអស់ ត្រូវគោរពតាមក្រមសីលធម៌ស្តីពីគណបក្សនយោបាយអោយបានសុក្រិតដើម្បីជៀសវាងអោយបាននូវភាពអយុត្តិធម៌ក្នុងការប្រកួតប្រជែងបោះឆ្នោត ។

**<u>សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនង</u>**

អ្នកស្រី ***ស៊ីនកេត ស៊ីរីលក្ខណ៍*** ( អ្នកសម្របសម្រួលផ្នែកអប់រំ និងយេនឌ័រ ខុមហ្វ្រែល)

ទូរស័ព្ទ : **(៨៥៥)-១៧-៤៩៤-00៤**